00749512

E95/8

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 26 / 10 / 2011
ម៉ោង (Time/Heure): 14:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ឆ្នាំ ២០០៧/អវតក/អជសដ
Case File/Dossier N° 002/19-09-2007/ECCC/TC

**ចំពោះមុខ** ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ អូតារ៉ា

**កាលបរិច្ឆេទ** ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១
**ភាសាដើម** ខ្មែរ/អង់គ្លេស/បារាំង
**ប្រភេទឯកសារ** សាធារណៈ

---

**សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃ ជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
អៀង សារី

E95/8

| | |
|---|---|
| | អៀង ធីរិទ្ធ |
| | ខៀវ សំផន |
| **<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>** | **<u>មេធាវីជនជាប់ចោទ</u>** |
| ពេជ អង្គ | សុន អរុណ |
| Elisabeth SIMONNEAU FORT | Michiel PESTMAN |
| | Victor KOPPE |
| | អាង ឧត្តម |
| | Michael G. KARNAVAS |
| | ផាត់ ពៅស៊ាង |
| | Diana ELLIS |
| | ស សុវាន |
| | Jacques VERGÈS |

## <u>១. សេចក្តីផ្តើម</u>

១. នៅក្នុងដីកាដំណោះស្រាយចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានដាក់បញ្ចូល ដោយពុំបានយោងលើលក្ខខណ្ឌតម្រូវថា អំពើជាក់លាក់នៃឧក្រិដ្ឋកម្មនេះ មានទំនាក់ទំនង ឬចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ឡើយ[១]។ ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ បានដាក់បណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសន្និដ្ឋាននេះ ទៅអង្គបុរេជំនុំជម្រះ ដោយលើកទឡ្ហីករណ៍ថា ចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ គឺជាផ្នែកមួយនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចាប់ពីឆ្នាំ ១៩៧៥-១៩៧៩[២]។ យោងតាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានទទួលយកមូលដ្ឋានមួយនេះនៅក្នុងបណ្តឹងឧទ្ធរណ៍ ដោយបានសម្រេចថា "ចំពោះច្បាប់ទំនៀមទម្លាប់អន្តរជាតិ វាមិនមានភាពច្បាស់លាស់ទេដែលថាតើលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ ត្រូវបានកាត់ផ្តាច់ឬទេ នៅមុនពេល ឬក្នុងអំឡុងពេលនៃយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក នោះ"[៣]។ អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះបានតម្កល់បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងដីកាដំណោះស្រាយដដែល ដោយបន្ថែមលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងរវាងអំពើជាក់លាក់ និងជម្លោះប្រដាប់អាវុធ[៤]។

២. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានទទួលសំណើពីសហព្រះរាជអាជ្ញា ស្នើសុំដកលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹង

---

[១] ដីកាដំណោះស្រាយ ឯកសារ D427 ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ កថាខណ្ឌ១៣៥០-១៣៧២។

[២] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/2/1 ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០ កថាខណ្ឌ៦១-៦២។

[៣] *សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះ ឯកសារ D427/3/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ១៣៧ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ")។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ កថាខណ្ឌ៣១១។

[៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ កថាខណ្ឌ១៤៨។

មនុស្សជាតិនៅក្នុងដីកាដំណោះស្រាយដែលបានកែប្រែ[៥]។ គ្រប់ក្រុមមេធាវីការពារក្តីទាំងអស់បានជំទាស់នឹងសំណើសុំនេះ[៦]។

## ២. សារណា

### ២.១ ភាពអាចទទួលយកបាន

៣. សហព្រះរាជអាជ្ញាសន្និដ្ឋានថា អនុលោមតាមវិធាន ៩៨(២)នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង មានសមត្ថកិច្ច និងកាតព្វកិច្ច ក្នុងការកែប្រែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ដែលបានកែប្រែ ដោយមិនចាំបាច់ដាក់បញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ[៧]។ ជនជាប់ចោទនៅក្នុងរឿងក្តីនេះ

---

[៥] សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ("សំណើរបស់សហព្រះរាជអាជ្ញា") ឯកសារ E95 ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១។ ដីកាដំណោះស្រាយ ឯកសារ D427 ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១០ (ការកែប្រែដោយសាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/3/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ និង សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១)("ដីកាដំណោះស្រាយកែប្រែ")។

[៦] ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកែប្រែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ("ចម្លើយតបរបស់ អៀង ធីរិទ្ធ") ឯកសារ E95/2 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ("ចម្លើយតបរបស់ នួន ជា") ឯកសារ E95/5 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ *ចម្លើយតបទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាដែលបានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងលុបចោលនូវលក្ខណៈវិនិច្ឆ័យដែលដាក់បញ្ចូលជម្លោះប្រដាប់អាវុធទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ* ("ចម្លើយតបរបស់ ខៀវ សំផន") ឯកសារ E95/3 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជ អាជ្ញាស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងសំណើសុំឱ្យមានសវនាការផ្ទាល់មាត់ ("ចម្លើយតបរបស់ អៀង សារី") ឯកសារ E95/4 ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ សំណើក្រោយនេះបានស្នើសុំបន្ថែមថាឱ្យបើកសវនាការដេញដោលលើបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងសំណើរបស់សហព្រះរាជអាជ្ញា។ *សូមមើល* ចម្លើយតបរបស់ អៀង សារី ទំព័រ១, ១៥។

[៧] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៦-៨ (ដកស្រង់រឿងក្តីនានាចេញពីតុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលបង្ហាញឱ្យឃើញថា ការកំណត់បទចោទសារជាថ្មីនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះអាចអនុញ្ញាតឱ្យធ្វើទៅបាន ដរាបណាជនជាប់ចោទ

បានដឹងថា ដោយផ្អែកតាមសំណើសុំនេះ អង្គជំនុំជម្រះសាលាដំបូងអាចនឹងមិនចាត់ទុកលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធថាជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ ដោយហេតុថាបញ្ហានេះមានការតវ៉ានៅក្នុងដំណាក់កាលមុនអង្គសេចក្តី និងដោយសារថាអង្គជំនុំជម្រះសាលាដំបូង ក៏មិនបានទាមទារលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងសំណុំរឿង ០០១ ដែរ[៨]។

៤. ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ ខៀវ សំផន និង អៀង សារី បានជំទាស់ថា សំណើសុំរបស់សហព្រះរាជអាជ្ញាមិនអាចទទួលយកបាន ពីព្រោះសំណើសុំនេះបង្កើតជាអញ្ញត្រកម្ម អនុលោមតាមវិធាន ៨៩(១)(ក)នៃវិធានផ្ទៃក្នុង ដែលកាលបរិច្ឆេទកំណត់លើកអញ្ញត្រកម្មនេះឡើង បានផុតយូរមកហើយ[៩]។ លើសពីនេះ សំណើសុំនេះគឺជាការប៉ុនប៉ងបន្តធ្វើបណ្តឹងជំទាស់ទៅលើសាលដីការបស់អង្គបុរេជំនុំជម្រះចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ដែលវិធានផ្ទៃក្នុងពុំអនុញ្ញាតឲ្យធ្វើដូច្នេះឡើយនៅដំណាក់កាលនេះ[១០]។ ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ និង ខៀវ សំផន សន្និដ្ឋានបន្ថែមទៀតថា សំណើសុំរបស់សហព្រះរាជអាជ្ញាមិនអាចទទួលយកបាន ដោយហេតុថា វិធាន ៩៨ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធតែចំពោះការកែប្រែបទចោទសារជាថ្មីលើអង្គហេតុ តែប៉ុណ្ណោះ ហើយវិធាននេះទៀតសោត ពុំអនុញ្ញាតឲ្យកែប្រែនិយមន័យនៃបទល្មើស ដែលអង្គជំនុំជម្រះមានយុត្តាធិការនោះឡើយ[១១]។

---

ត្រូវបានជូនដំណឹងអំពីលទ្ធភាពដែលថា ការកំណត់បទចោទលើអង្គហេតុ អាចត្រូវបានកែប្រែ និងដរាបណាជនជាប់ចោទមានឱកាសរៀបចំការការពារក្តីទៅតាមការកែប្រែនោះ។

[៨] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៩។

[៩] ចម្លើយតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌ៤-៩។ ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ៦-១៨។ ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ១៤-១៨។

[១០] ចម្លើយតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌ៩។ ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ១៧-១៨។ ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ១៤-១៨។

[១១] ចម្លើយតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌ១០។ ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ៨, ១០-១១ (បានអះអាងបន្ថែមទៀតថា វិធាន ៩៨ នៃវិធានផ្ទៃក្នុង មិនអាចអនុវត្តបាន ដោយហេតុថាវិធាននេះផ្តល់អំណាចជូនអង្គជំនុំជម្រះសាលាដំបូង ពុំមែនជូនសហព្រះរាជអាជ្ញា សម្រាប់កែប្រែលើការកំណត់បទចោទលើអង្គហេតុ នៅក្នុងដំណាក់កាលជំនុំជម្រះនោះទេ។

៥. សហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងការឆ្លើយតបរបស់ខ្លួនថា វិធាន ៨៩ នៃវិធានផ្ទៃក្នុង ពុំបានកម្រិតលទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងការពិចារណាឱ្យបានទូលំទូលាយជាងមុនលើបញ្ហាយុត្តាធិការ នៅក្នុងសំណើសុំកំណត់បទចោទឡើងវិញនោះឡើយ[១២]។ ទោះបីជាបានទទួលស្គាល់ថា សាលដីការបស់អង្គបុរេជំនុំជម្រះ ពុំបើកផ្លូវឱ្យប្តឹងតវ៉ាក៏ដោយ ក៏សាលដីកាទាំងនោះ ពុំចងកាតព្វកិច្ចឱ្យអង្គជំនុំជម្រះសាលាដំបូងគោរពតាមឡើយ ហើយក៏ពុំអាចរារាំងអង្គជំនុំជម្រះសាលាដំបូង មិនឱ្យអនុវត្តសមត្ថកិច្ចរបស់ខ្លួនក្នុងការពិចារណាលើអង្គច្បាប់ ដែលអង្គបុរេជំនុំជម្រះបានសម្រេចរួចមកហើយនោះដែរ[១៣]។ លើសពីនេះ អង្គជំនុំជម្រះសាលាដំបូង មានសិទ្ធិក្នុងការកំណត់បទល្មើសនៅក្នុងរឿងក្តីនេះឡើងវិញបាន និងមានភារកិច្ចអនុវត្ត និងបញ្ជាក់អំពីច្បាប់ដែលពាក់ព័ន្ធឱ្យបានច្បាស់។ អង្គជំនុំជម្រះសាលាដំបូង គួរអនុវត្តភារកិច្ចនេះ ដោយធ្វើការកែប្រែនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដើម្បីឱ្យវាឆ្លុះបញ្ចាំងស្របទៅតាមច្បាប់ជាធរមាន[១៤]។

## ២.២ ខ្លឹមសារនៃបណ្តឹង

៦. សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ពុំបានដាក់បញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនោះឡើយ[១៥]។ និយមន័យនេះ ស្របទៅតាមគោលការណ៍នីត្យានុកូលភាព ពីព្រោះច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ពុំទាមទារនូវ

---

[១២] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនានារបស់មេធាវីការពារក្តីលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកំណត់បទចោទជាថ្មីឡើងវិញក្នុងដីកាដំណោះស្រាយ និងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឯកសារ E95/6 ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១១ ("ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ១៦។

[១៣] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៤។

[១៤] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៣១, ៣៣ និង៣៨ ("គុលាការអនុវត្តច្បាប់")។

[១៥] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៤។

លក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ[១៦]។ ម្យ៉ាងវិញទៀត អង្គបុរេជំនុំជម្រះបាន ដោះស្រាយបញ្ហានេះដោយពុំត្រឹមត្រូវ ដោយយោងលើរបៀបនៃការបកស្រាយមួយ ដែលទាមទារឱ្យផ្តល់ប្រយោជន៍ដល់ជនជាប់ចោទក្នុងករណីមានវិមតិសង្ស័យ។ វិធីនៃការបកស្រាយបែបនេះ ពុំអាចអនុវត្តបានទេចំពោះបញ្ហាថាតើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងឆ្នាំ ១៩៧៥ តម្រូវ ឬមិនតម្រូវឱ្យមានលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ដែរឬយ៉ាងណានោះ[១៧]។

៧. ក្រុមមេធាវីការពារក្តី អៀង សារី ច្រានចោលការបកស្រាយដូច្នេះរបស់សហព្រះរាជអាជ្ញាលើស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិចំពោះអំឡុងពេលដែលពាក់ព័ន្ធ។ ការច្រានចោលនេះគឺដោយផ្អែកតាមធម្មនុញ្ញរបស់តុលាការ Nuremberg ដែលបានដាក់បញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ[១៨] និងដោយបានផ្អែកទៅតាមការបកស្រាយរបស់ខ្លួនលើរឿងក្តី

---

[១៦] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៦-២៦ (កត់សម្គាល់ឃើញថា ការបញ្ចូលទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងធម្មនុញ្ញនៃសាលាក្តីយោធាអន្តរជាតិ គឺគ្រាន់តែជាលក្ខខណ្ឌយុត្តាធិការតែប៉ុណ្ណោះ ហើយច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យអាឡឺម៉ង់ ("ច្បាប់លេខ ១០") រួមជាមួយនឹងរឿងក្តី *Einsatzgruppen* និងរឿងក្តី *Justice* បានសម្រេចដោយផ្អែកលើមូលដ្ឋាននេះ បានអនុញ្ញាតឱ្យធ្វើការចោទប្រកាន់ ដោយពុំមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ។ ម្យ៉ាងវិញទៀត អនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីប្រល័យពូជសាសន៍ (អនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីការបង្ការ និងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៤៨ 78 UNTS 277 មាត្រា ១ ("អនុសញ្ញាស្តីពីប្រល័យពូជសាសន៍")) អនុសញ្ញាឆ្នាំ ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍ (អនុសញ្ញាអន្តរជាតិឆ្នាំ ១៩៤៨ ស្តីពីការបង្ក្រាប និងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៣ 1015 UTNS 243 មាត្រា ១ ("អនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍") និងអនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីអាជ្ញាយុកាល មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ២៣៩១ (XXVIII) ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៦៨ ឧបសម្ព័ន្ធ មាត្រា I(ខ) ("អនុសញ្ញាស្តីពីអាជ្ញាយុកាល")) មិនបានបញ្ចូលទំនាក់ទំនងជម្លោះប្រដាប់អាវុធ ជាលក្ខខណ្ឌនៅក្នុងនិយមន័យនីមួយៗនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។ សេចក្តីព្រាងក្រមរបស់គណៈ-កម្មាការនីតិកម្មអន្តរជាតិឆ្នាំ ១៩៥៤ ស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ UN Doc. A/2693 (ឆ្នាំ ១៩៥៤) ("សេចក្តីព្រាងក្រមរបស់គណៈកម្មាការនីតិកម្មអន្តរជាតិ ឆ្នាំ ១៩៥៤") បានកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយទាមទារនូវទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ។

[១៧] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២៧-៣២ ("វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ")។

[១៨] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ២១-២២។ ក្រុមមេធាវីការពារក្តី បានយោងលើសារណារបស់ក្រុមមេធាវីការពារក្តី អៀង សារី និង អៀង ធីរិទ្ធ។ *សូមមើល* ចម្លើយតបរបស់ នួន ជា កថាខណ្ឌ៥។

*Einsatzgruppen, Justice* និង *Flick*[១៩]។ ការមិនដាក់បញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ នៅក្នុងអនុសញ្ញាស្ដីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺពុំមានការពាក់ព័ន្ធទេ ដោយសារតែឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានធាតុផ្សំនីត្យានុកូលខុសគ្នា[២០]។ ម្យ៉ាងវិញទៀត អនុសញ្ញាស្ដីពីការប្រកាន់ពូជសាសន៍ ពុំគាំទ្រការដកចេញលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ នៅត្រឹមឆ្នាំ ១៩៧៥ ផងដែរ ដោយហេតុថា អនុសញ្ញានេះពុំត្រូវបានចុះហត្ថលេខាដោយប្រទេសណាមួយនៅប៉ែកខាងលិច នៅត្រឹមពេលដែលអនុសញ្ញានេះបានចូលជាធរមាននៅក្នុងខែ កក្កដា ឆ្នាំ ១៩៧៦[២១]។ អ្នកធ្វើសេចក្ដីព្រាងឆ្នាំ ១៩៥៤ របស់គណៈកម្មការនីតិកម្មអន្តរជាតិ បានទទួលស្គាល់ថា និយមន័យដែលបានអនុម័តនោះពុំបានឆ្លុះបញ្ចាំងអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនាពេលនោះឡើយ ចំណែកឯអនុសញ្ញាស្ដីពីអាជ្ញាយុកាល គឺជាឯកសារនយោបាយមួយប៉ុណ្ណោះ ដែលបានអូសទាញការគាំទ្រពីបណ្ដាប្រទេសជាសមាជិក អ.ស.ប មិនដល់ពាក់កណ្ដាលផងនោះ។ ទោះក្នុងករណីណាក៏ដោយ មានតែឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍ប៉ុណ្ណោះដែលមិនតម្រូវឲ្យគោរពតាមនូវលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ[២២]។ ក្រុមមេធាវីការពារក្ដី ខៀវ សំផន សន្និដ្ឋានថា ការចរចាឈានទៅរកការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ (“តុលាការ ICC”) នៅចន្លោះឆ្នាំ ១៩៩៣ ដល់ ឆ្នាំ ១៩៩៨ គាំទ្រចំពោះការសន្និដ្ឋានថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

---

[១៩] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ២៣-២៤។

[២០] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ២៦ (ដាក់បញ្ចូលដោយយោងលើសារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ឯកសារ D427/1/23 ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០ កថាខណ្ឌ៨៨។ (“សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍”)។

[២១] សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៨៨។

[២២] ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ២៧-២៩។ សារណាឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៩០ (បានអះអាងបន្ថែមទៀតថា ប្រភពទាំងនេះកើតចេញមកពីច្បាប់ជាតិ ដូចជា ច្បាប់អ៊ីស្រាអែល ឆ្នាំ ១៩៥០ ដែលបានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចបានដកស្រង់នៅក្នុងសំណើសុំរបស់សហព្រះរាជអាជ្ញា ត្រង់កថាខណ្ឌ ២៣ មិនអាចចាត់ទុកជាសេចក្ដីប្រកាសនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ)។

បានរក្សាទុកលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ នៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[២៣]។ របាយការណ៍នៃគណៈកម្មាការនីតិកម្មអន្តរជាតិ និងគណៈកម្មាធិការ *មិនអចិន្ត្រៃយ៍* ស្តីពីការបង្កើតតុលាការ ICC បង្ហាញថា រដ្ឋសមាជិកមានការយល់ឃើញខុសៗគ្នា ចំពោះករណីថាតើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានទាមទារនូវលក្ខខណ្ឌទំនាក់ ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធដែរ ឬទេ នៅក្នុងអំឡុងឆ្នាំនោះ[២៤]។ ក្រុមមេធាវីការពារក្តីនីមួយៗ អះអាងថា គោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺជាគោលការណ៍ នៃច្បាប់អន្តរជាតិដែលបានបង្កើតឡើង ហើយត្រូវយកមកអនុវត្តចំពោះបញ្ហានេះនៅក្នុងករណីមានវិមតិសង្ស័យ[២៥]។

៨. សហព្រះរាជអាជ្ញាបានសន្និដ្ឋាននៅក្នុងការឆ្លើយតបរបស់ខ្លួនថា គោលការណ៍ទាំងឡាយដែលចេញពីធម្មនុញ្ញNuremberg គ្រាន់តែតំណាងនូវគោលការណ៍ច្បាប់សម្រាប់សាលាក្តី Nuremberg អនុវត្តតែប៉ុណ្ណោះ។ គោលការណ៍ទាំងនេះ ពុំឆ្លុះបញ្ចាំងជាសំខាន់នូវស្ថានភាពនៃច្បាប់ទំនៀមទម្លាប់ឡើយ[២៦]។ ការដែលថា ក្រុមគណៈប្រតិភូបានបង្ហាញនូវទស្សនៈខុសៗគ្នា នៅពេលពិភាក្សាលើលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ នៅពេលចរចាឈានទៅរកការអនុម័តលក្ខន្តិកៈ ICC គឺវាមិនមានលក្ខណៈគ្រប់គ្រាន់អាចឲ្យយើងកែប្រែខ្លឹមសារនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលផ្អែកលើភាពស៊ីសង្វាក់គ្នានៃការអនុវត្តរបស់រដ្ឋ ពុំមែនផ្អែកលើការអនុវត្តជាឯកច្ឆ័ន្ទរបស់រដ្ឋនានានោះទេ[២៧]។ សេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ របស់គណៈកម្មាធិការនីតិកម្មអន្តរជាតិបានផ្តល់ជា "ភស្តុតាងយ៉ាងមានតម្លៃបង្ហាញជាទស្សនៈរួមមួយរបស់អ្នកនិពន្ធល្បីៗដែលបានលើក

---

[២៣] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ២១។

[២៤] ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ២២។

[២៥] ចម្លើយតបរបស់ អៀង ធីរិទ្ធ កថាខណ្ឌ១៨-២៤។ ចម្លើយតបរបស់ អៀង សារី កថាខណ្ឌ៣២-៣៤។ ចម្លើយតបរបស់ នួន ជា កថាខណ្ឌ៥-២១។

[២៦] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៤៦-៤៧ (បានកត់សម្គាល់របាយការណ៍របស់គណៈកម្មាការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ ដែលបានសន្និដ្ឋានថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចកើតឡើងនៅក្នុងពេលសន្តិភាព ប៉ុន្តែ ធម្មនុញ្ញ Nuremberg បានរឹតរឹសាលភាពនៃនិយមន័យឧក្រិដ្ឋកម្មនេះ)។

[២៧] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៤៩។

ឡើងអំពីការអនុវត្តរបស់រដ្ឋ និងអំពី*សច្ចធារណ៍ផ្លូវច្បាប់* ចំពោះបញ្ញាលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ"[២៨]។ ចំនួនភាគីនៃអនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍ ពុំមែនជាកត្តាកំណត់ជាក់លាក់ឡើយ ដោយហេតុថាយើងក៏ត្រូវយកការអនុវត្តរបស់រដ្ឋមកពិចារណាផងដែរ[២៩]។ ច្បាប់ និងកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក ក៏ផ្តល់ "ជាភស្តុតាងពាក់ព័ន្ធនឹងការយល់ឃើញនាពេលបច្ចុប្បន្នរបស់ប្រទេសជាសមាជិក អ.ស.ប រួមមាន ប្រទេសកម្ពុជាផងដែរ ព្រមទាំងផ្តល់ជាភស្តុតាងបង្ហាញនូវទស្សនៈរបស់អ្នកសិក្សាស្រាវជ្រាវល្បីៗ ដែលបានសិក្សាលើលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់ក្នុងអំឡុងពេលពាក់ព័ន្ធ"[៣០]។

## ៣. សំអាងហេតុ

### ៣.១. ភាពអាចទទួលយកបាន

៩. អង្គជំនុំជម្រះសាលាដំបូង មានភារកិច្ចពិនិត្យមើលថាតើអំពើទាំងឡាយដែលបានប្រព្រឹត្តដោយជនជាប់ចោទ គឺជាបទឧក្រិដ្ឋដែរ ឬទេ[៣១] ព្រមទាំងមានភារកិច្ចអនុវត្តច្បាប់ជាធរមានឲ្យបានត្រឹមត្រូវផងដែរ នៅពេលដែលអំពើទាំងនោះបានកើតឡើង ដោយធ្វើយ៉ាងណាឲ្យស្របទៅតាមគោលការណ៍នីត្យានុកូលភាព[៣២]។ ការសម្រេចនេះ គឺជាសិទ្ធិអំណាចដោយផ្ទាល់របស់អង្គជំនុំជម្រះ-សាលាដំបូង។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ទោះក្នុងករណីណាក៏ដោយ

---

[២៨] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៥៧។

[២៩] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៦៣-៦៤ (កត់សម្គាល់បន្ថែមទៀតថា *ការងាររៀបចំ*នៃអនុសញ្ញាស្តីពីអាជ្ញាយុកាល ក៏បានលើកឡើងពីការជំទាស់ចំបងលើអនុសញ្ញានេះថា វាមិនសមស្របដើម្បីពង្រីកប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រៅពីជាធាតុសំខាន់មួយរបស់វា)។

[៣០] ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៦៩។

[៣១] *សូមមើល* វិធាន៩៨(៣)នៃវិធានផ្ទៃក្នុង។

[៣២] *សូមមើលឧទាហរណ៍ យុត្តាធិការ Fisheries* សាលក្រម របាយការណ៍ ត.យ.អ ឆ្នាំ ១៩៧៤ ទំព័រ ១៧៥ ("[វា][ជា]ភារកិច្ចរបស់តុលាការខ្លួនឯង ដែលត្រូវបញ្ជាក់ និងអនុវត្តច្បាប់ពាក់ព័ន្ធនៅក្នុងកាលៈទេសៈជាក់លាក់នៃរឿងក្តី បន្ទុកនៃការបង្កើត ឬ បង្ហាញវិធានច្បាប់អន្តរជាតិ មិនអាចដាក់មកលើភាគីណាមួយឡើយ ដោយសារច្បាប់គឺស្ថិតនៅក្នុងការយល់ដឹងរបស់តុលាការ")។

អង្គជំនុំជម្រះអាចសម្រេចលើច្បាប់ដែលអនុវត្តនៅក្នុងរឿងក្តីនេះ ដោយរួមទាំងការសម្រេចលើធាតុផ្សំនៃបទល្មើស ដូចមានចែងនៅក្នុងដីកាដំណោះស្រាយ ដើម្បីធ្វើយ៉ាងណាឲ្យមានលក្ខណៈត្រឹមត្រូវទៅតាមស្ថានភាពនៃច្បាប់ ហើយការសម្រេចនេះក៏ត្រូវគោរពទៅតាមលក្ខខណ្ឌចាំបាច់នៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ផងដែរ[៣៣]។ ដោយហេតុថា សំណើសុំរបស់សហព្រះរាជ-អាជ្ញា បានលើកឡើងអំពីការកែប្រែលើធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅមុនពេលចាប់ផ្តើមការជំនុំជម្រះលើអង្គសេចក្តី ហេតុដូច្នេះ វាពុំមានភាពអយុត្តិធម៌សម្រាប់ជនជាប់-ចោទនោះទេ ប្រសិនបើអង្គជំនុំជម្រះសម្រេចយកសំណើសុំរបស់សហព្រះរាជអាជ្ញាមកពិចារណានៅក្នុងពេលនេះ[៣៤]។

## ៣.២. លក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ)

### ៣.២.១ សេចក្តីផ្តើម

១០. វាជាការដែលមិនអាចប្រកែកបានដែលថា នាពេលបច្ចុប្បន្ននេះ លក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ពុំមែនជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ[៣៥]។ មាត្រា ៥ នៃច្បាប់ អ.វ.ត.ក ក៏ពុំបានបញ្ចូលលក្ខខណ្ឌទំនាក់ទំនងជា

---

[៣៣] នៅក្នុងបរិបទជាក់លាក់របស់ អ.វ.ត.ក ករណីនេះទាមទារឲ្យតុលាការកំណត់នៅក្នុងលក្ខខណ្ឌវិតត្បិតនៃអង្គហេតុ ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ (*សូមមើល* វិធាន ៩៨(២)នៃវិធានផ្ទៃក្នុង)៖ "សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទ ដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំនៃបទចោទបានឡើយ")។

[៣៤] សាលក្រម *ឌុច* កថាខណ្ឌ ៥០១-៥០៣ (រកឃើញថា ការកំណត់បទចោទឡើងវិញ មិនរំលោភបំពានលើសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ ដោយហេតុថាជនជាប់ចោទនៅក្នុងរឿងក្តីនេះបានទទួលការជូនដំណឹងថា បញ្ហានៃសហឧក្រិដ្ឋកម្មរួម បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះមានបំណងសម្រេចលើបញ្ហានេះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន)។

[៣៥] *សូមមើលឧទាហរណ៍* លក្ខន្តិកៈទីក្រុងរ៉ូមឆ្នាំ ១៩៩៨ មាត្រា ៧ (ដែលមិនបានដាក់បញ្ចូលទំនាក់ទំនងជម្លោះប្រដាប់អាវុធនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។ រដ្ឋហត្ថលេខីមានចំនួន ១៣៩ ហើយរដ្ឋភាគីមានចំនួន ១១៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម។ *សូមមើលផងដែរនូវ* លក្ខន្តិកៈរបស់សាលាក្តី ICTR មាត្រា ៣។ លក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន មាត្រា ២។ *ព្រះរាជអាជ្ញា ទល់នឹង Tadić* សាលដីកាលើសំណើសុំរបស់ក្រុមមេធាវីការពារក្តីលើបណ្តឹងសាទុក្ខសេចក្តីសម្រេចលើទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ/២៦ ខែ តុលា ឆ្នាំ ២០១១ /សាធារណៈ

មួយនឹងជម្លោះប្រដាប់អាវុធទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សមនុស្សជាតិដែរ[៣៦]។ ដើម្បីអនុវត្តឲ្យស្របតាមគោលការណ៍នីត្យានុកូលភាព អង្គជំនុំជម្រះសាលាដំបូងត្រូវតែបញ្ជាក់ឲ្យបានច្បាស់ថាតើ ការមិនដាក់បញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឆ្លុះបញ្ចាំងនូវស្ថានភាពច្បាប់ជាតិ និងអន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ដែរ ឬទេ[៣៧]។

១១. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើបញ្ហានេះនៅក្នុងសាលក្រម *ឌុច* ទៅតាមគំនិតផ្តួចផ្តើមរបស់ខ្លួន ដោយយល់ឃើញថា និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងច្បាប់ទំនៀម-ទម្លាប់អន្តរជាតិ ពុំទាមទារនូវលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធនោះឡើយ[៣៨]។ ទោះបីជាធម្មនុញ្ញ Nuremberg ទាមទារលក្ខខណ្ឌទំនាក់ទំនងជម្លោះប្រដាប់អាវុធចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ ក៏លក្ខខណ្ឌនេះ មិនត្រូវបានដាក់បញ្ចូលនៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យប្រទេសអាឡឺម៉ង់ឡើយ។ ម្យ៉ាងវិញទៀត អនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ សេចក្តីព្រាងក្រមឆ្នាំ ១៩៥៤ របស់គណៈកម្មការនីតិកម្មអន្តរជាតិ អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីអាជ្ញាយុកាល និងអនុសញ្ញាឆ្នាំ ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍ បានបំបាត់ចោលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធទាំងអស់នៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ជាចុងក្រោយ

---

បន្ទាន់បង្ខំស្តីពីយុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូលរបស់សាលាក្តី ICTY (រឿងក្តីលេខ IT-94-1-A) ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៥ កថាខណ្ឌ ១៤០ ("បណ្តឹងសាទុក្ខបន្ទាន់បង្ខំរបស់ *Tadić*")។

[៣៦] មាត្រា ៥ នៃច្បាប់ អ.វ.ត.ក ចែងថា៖ "អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាលគឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬ ដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា ណាមួយដូចជា៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា អំពើអមនុស្សធម៌ផ្សេងៗទៀត"។

[៣៧] សាលក្រម *ឌុច* កថាខណ្ឌ ២៨៣។

[៣៨] សាលក្រម *ឌុច* កថាខណ្ឌ ២៩១។

អង្គជំនុំជម្រះសាលាដំបូងបានដកស្រង់យុត្តិសាស្ត្ររបស់តុលាការ ICTY សេចក្តីសម្រេចរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងរបាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជាដើម្បីបង្ហាញថា លក្ខខណ្ឌទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធលែងបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទៀតហើយ ចាប់ពីឆ្នាំ ១៩៧៥[៣៩]។

១២. ក្រោយពីបានវាយតម្លៃលើខ្លឹមសារនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងពេលដែលពាក់ព័ន្ធ អង្គជំនុំជម្រះយល់ឃើញថា ពុំមានមូលដ្ឋានចាំបាច់ណាមួយត្រូវពិចារណាឡើងវិញលើបញ្ហាដដែលនេះទៀតទេចំពោះអ្វីដែលអង្គជំនុំជម្រះបានសម្រេចរួចហើយនៅក្នុងសំណុំរឿង០០១ នោះ។ អង្គជំនុំជម្រះផ្តល់នូវសំអាងហេតុមួយចំនួនដូចខាងក្រោម[៤០]។

### ៣.២.២ ធម្មនុញ្ញ *Nuremberg* និងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ

១៣. និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងធម្មនុញ្ញ Nuremberg ទាមទារនូវលក្ខខណ្ឌរវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងបទល្មើសណាមួយ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ (*ពោលគឺ* ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងឧក្រិដ្ឋកម្មសង្គ្រាម)។ ពាក្យពេចន៍ប្រើប្រាស់នៅក្នុងសាលក្រមរបស់តុលាការ Nuremberg មានលក្ខណៈស្រពិចស្រពិលចំពោះករណីថាតើលក្ខខណ្ឌទំនាក់ទំនងនៅក្នុងធម្មនុញ្ញ Nuremberg គឺជាលក្ខខណ្ឌយុត្តាធិការនៅក្នុងធម្មនុញ្ញ Nuremberg តែប៉ុណ្ណោះ ឬ ក៏ជាលក្ខខណ្ឌសម្រាប់ការអនុវត្តក្នុងន័យទូលាយជាងនេះ៖

---

[៣៩] សាលក្រម *ឌុច* កថាខណ្ឌ ២៩២។

[៤០] ខ្លឹមសារនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ កើតចេញពីការអនុវត្តជាក់ស្តែងរបស់រដ្ឋ និង*សច្ចធារណ៍ធម្មានុរូប*។ *សូមមើល រឿងក្តីខ្ពង់រាបសមុទ្រខាងជើង* (ឆ្នាំ ១៩៦៩) សាលក្រម អ.យ.អ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៦៩ ទំព័រ ៤៣-៤៤ កថាខណ្ឌ ៧៤ ("ការអនុវត្តរបស់រដ្ឋ រួមទាំង ការអនុវត្តរបស់រដ្ឋ ដែលផលប្រយោជន៍របស់ខ្លួនរងការប៉ះពាល់ គួរតែជាការអនុវត្តទូទៅ និងរួមយោងតាមស្មារតីនៃបទប្បញ្ញត្តិ ដែលបានលើកឡើង និង ម្យ៉ាងវិញទៀត គួរបានកើតឡើងនៅក្នុងរបៀបមួយ បង្ហាញជាការទទួលស្គាល់ទូទៅថាមានការជាប់ពាក់ព័ន្ធនឹងវិធានច្បាប់ ឬ កាតព្វកិច្ចផ្លូវច្បាប់។ [...] អំពើដែលពាក់ព័ន្ធ មិនត្រូវតែជាការអនុវត្តរបស់រដ្ឋនោះទេ ប៉ុន្តែ វាត្រូវជាអំពើ ឬ ត្រូវអនុវត្តក្នុងទម្រង់មួយ ដែលបង្ហាញជាភស្តុតាងឲ្យជឿជាក់ថា ការអនុវត្តនេះគឺជាកាតព្វកិច្ច ដែលច្បាប់ទាមទារឲ្យអនុវត្តដូច្នេះ [*សច្ចធារណ៍ធម្មានុរូប*]។ ប្រភពច្បាប់ទំនៀមទម្លាប់អន្តរជាតិពាក់ព័ន្ធ រួមមានអនុសញ្ញា និងសន្ធិសញ្ញា សេចក្តីប្រកាសរបស់គណៈប្រតិភូ ក្នុងពេលចរចាសន្និសញ្ញា និងយុត្តិសាស្ត្រនៃសាលាក្តីអន្តរជាតិ។ *សូមមើល ឧទាហរណ៍ រឿងក្តីពាក់ព័ន្ធនឹងសកម្មភាពយោធា និងយោធាប្រតិព័ទ្ធនៅក្នុង និងប្រឆាំងនឹងនីការ៉ាហ្គ័រ* សាលក្រម ត.យ.អ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៨៦ (របាយការណ៍ ត.យ.អ ឆ្នាំ ១៩៨៦ ទំព័រ ៩៨-១០១ កថាខណ្ឌ ១៨៥-១៩១"។

ដើម្បីបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើទាំងឡាយ ដែលបានយកមកសំអាងនៅមុនពេលសង្គ្រាមផ្ទុះឡើង ត្រូវតែបានប្រព្រឹត្តឡើង ឬ ជាប់ទាក់ទងនឹងបទល្មើសណាមួយ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់សាលាក្តីនេះ។ សាលាក្តីនេះយល់ឃើញថា ទោះបីជាអំពើទាំងនេះគួរឱ្យរន្ធត់ និងស្អប់ខ្ពើមយ៉ាងណាក៏ដោយ វានៅមិនទាន់បង្ហាញឱ្យតុលាការនេះជឿជាក់ថាតើអំពើទាំងនេះបានប្រព្រឹត្តឡើង ឬ ជាប់ពាក់ព័ន្ធនឹងបទល្មើសជាក់លាក់ណាមួយនៅឡើយ។ ហេតុដូច្នេះ សាលាក្តីនេះ មិនអាចប្រកាសជាទូទៅថា អំពើមុនឆ្នាំ ១៩៣៩ គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ *នៅក្នុងនិយមន័យនៃធម្មនុញ្ញនេះឡើយ*។ ក៏ប៉ុន្តែ ចាប់តាំងពីការចាប់ផ្តើមសង្គ្រាមនៅក្នុងឆ្នាំ ១៩៣៩ មក ឧក្រិដ្ឋកម្មសង្គ្រាមបានប្រព្រឹត្តឡើងក្នុងទម្រង់ធំធេង *ដែលក៏អាចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផងដែរ។* ពាក់ព័ន្ធនឹងអំពើអមនុស្សធម៌ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយដែលត្រូវបានប្រព្រឹត្តក្រោយការចាប់ផ្តើមនៃសង្គ្រាម អំពើអមនុស្សធម៌ទាំងនេះពុំមែនជាឧក្រិដ្ឋកម្មសង្គ្រាមនោះទេ អំពើទាំងនេះបានប្រព្រឹត្តឡើងក្នុងពេលធ្វើសង្គ្រាមឈ្លានពាន ឬ ជាប់ពាក់ព័ន្ធនឹងសង្គ្រាមឈ្លានពាន ហេតុដូច្នេះ វាបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៤១] (គូសបញ្ជាក់បន្ថែម)

១៤. យោងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ អំពើដំបូងៗនៅក្នុងសង្គ្រាមឈ្លានពាន បានកើតឡើងនៅក្នុងថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៣៩[៤២]។ ហេតុដូច្នេះ តុលាការបានសម្រេចថា មានតែឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានប្រព្រឹត្តក្រោយអំពើដំបូងៗនៅក្នុងសង្គ្រាមឈ្លានពាននៅក្នុងឆ្នាំ ១៩៣៩ តែប៉ុណ្ណោះ ដែលមានការជាប់ពាក់ព័ន្ធ ឬ ដែលត្រូវបានចាត់ទុកថាប្រព្រឹត្តឡើងក្នុងសង្គ្រាមឈ្លានពាននេះ។ នៅពេលសន្និដ្ឋានថា អំពីទាំងឡាយដែលបានកើតឡើងមុនពេលចាប់ផ្តើមអរិភាពក្នុងឆ្នាំ ១៩៣៩ ពុំបានបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ យោងតាមអត្ថន័យនៃធម្មនុញ្ញ Nuremberg នោះ តុលាការ Nuremberg ទំនងជាបានកម្រិតខ្លួនឯងយ៉ាងតឹងរ៉ឹងលើពាក្យពេចន៍ប្រើប្រាស់នៅក្នុងធម្មនុញ្ញ។ តុលាការនេះពុំបានវាយតម្លៃលើខ្លឹមសារនៃច្បាប់ទំនៀមទម្លាប់

---

[៤១] ការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមធំៗនៅចំពោះមុខសាលាក្តីយោធាអន្តរជាតិ វ៉ុលលីម ២២ ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៤៦ ("សាលក្រម Nuremberg") ទំព័រ ៤៩៨។

[៤២] សាលក្រម Nuremberg ទំព័រ ៤២៧។

អន្តរជាតិ ដែលទំនងជាអាចមានអត្ថិភាពនៅក្រៅវង្វង់នៃការរឹតត្បិតនេះ[៤៣]។

១៥. ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យបានដកចេញនូវលក្ខខណ្ឌកម្រិត ដែលថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវតែបានប្រព្រឹត្តឡើង ដោយជាប់ពាក់ព័ន្ធនឹងបទល្មើសណាមួយដែលស្ថិតក្រោមយុត្តាធិការរបស់តុលាការ (ដូចជា ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬឧក្រិដ្ឋកម្មសង្គ្រាម)[៤៤]។ នៅពេលវាយតម្លៃអំពីវិសាលភាពនៃសមត្ថកិច្ចរបស់ខ្លួន តុលាការមួយចំនួន ដែលត្រូវបានបង្កើតឡើង អនុលោមតាមច្បាប់លេខ ១០ នៃក្រុមប្រឹក្សាត្រួតពិនិត្យ បានបកស្រាយលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងធម្មនុញ្ញ Nuremberg ថាជាលក្ខខណ្ឌយុត្តាធិការ[៤៥]។ នៅក្នុងរឿងក្តី *សហរដ្ឋអាមេរិក ទល់នឹង Flick* តុលាការបានពិចារណាថា កិច្ចព្រមព្រៀងទីក្រុងឡុងដ៍ ដែលកើតចេញពីការពង្រីកបន្ថែមលើធម្មនុញ្ញ Nuremberg បានដាក់បញ្ចូលខ្លឹមសារនៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យអាឡឺម៉ង់[៤៦] និងបានកត់សម្គាល់ឃើញថា តុលាការ Nuremberg "បានបដិសេធមិនទទួលយកយុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានកើតឡើងនៅមុនថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៣៩"[៤៧]។ តុលាការបានផ្តល់ជាសំអាងហេតុថា "ស្មារតី [...] នៃធម្មនុញ្ញនេះមានគោលបំណងចែងអំពីការដាក់ទណ្ឌកម្មចំពោះបទល្មើសទាំងឡាយ

---

[៤៣] អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា មាត្រា ៥(គ)នៃធម្មនុញ្ញរបស់សាលាក្តីយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ("សាលាក្តីយោធាអន្តរជាតិ") មាននិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្រដៀងគ្នា។

[៤៤] ច្បាប់លេខ ១០ ស្តីពីការដាក់ទណ្ឌកម្មលើពិរុទ្ធជនឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥ មាត្រា II (១)(គ)។

[៤៥] រឿងក្តី *Flick និងជនផ្សេងទៀត* សាលក្រមចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៤៧ បានបោះពុម្ពឡើងវិញនៅក្នុង*ការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធាអន្តរជាតិ Nuremberg អនុលោមតាមច្បាប់លេខ ១០* វ៉ុលលីម VI ("រឿងក្តី *Flick និងជនផ្សេងទៀត*") ទំព័រ ១២១២-១២១៣។ រឿងក្តី *Ohlendorf និងជនផ្សេងទៀត (ការជំនុំជម្រះលើរឿងក្តី Einsatzgruppen)* សាលាក្រម ចុះថ្ងៃទី ០៨-០៩ ខែ មេសា ឆ្នាំ ១៩៤៨ បោះពុម្ពឡើងវិញនៅក្នុង*ការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខសាលាក្តីយោធា* Nuernberg ក្រោមច្បាប់លេខ ១០ វ៉ុលលីម IV ("រឿងក្តី *Ohlendorf និងជនផ្សេងទៀត*") ទំព័រ ៤៩៩។

[៤៦] រឿងក្តី*Flick និងជនផ្សេងទៀត* ទំព័រ ១២១២-១២១៣។

[៤៧] រឿងក្តី*Flick និងជនផ្សេងទៀត* ទំព័រ ១២១២-១២១៣។

ដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលមានសង្គ្រាម និងជាប់ពាក់ព័ន្ធនឹងសង្គ្រាម [...]"។ ការងារដ៏ធំធេងរបស់តុលាការនេះ គឺការកាត់សេចក្តីលើឧក្រិដ្ឋកម្មសង្គ្រាម ដោយហេតុថា ការចោទប្រកាន់ជាច្រើនបានបង្ហាញថា វាពុំមានភាពចាំបាច់ ឬ វាពុំមានហេតុផលអ្វីដែលត្រូវរំពឹងថា តុលាការនេះនឹងយកបុគ្គលទាំងឡាយមកជំនុំជម្រះពីបទល្មើសនានាដែលពុំពាក់ព័ន្ធនឹងសង្គ្រាមនោះឡើយ"[៤៨]។ ជាបច្ច័យ តុលាការនេះបានបដិសេធចោលចំពោះការចោទប្រកាន់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយផ្អែកលើមូលដ្ឋានថា បទល្មើសដែលត្រូវបានចោទប្រកាន់ ត្រូវបានប្រព្រឹត្តឡើងមុនសង្គ្រាម។

១៦. ការពិចារណាដូចគ្នាចំពោះលក្ខខណ្ឌនៃជម្លោះប្រដាប់អាវុធនៅក្នុងធម្មនុញ្ញ Nuremberg បានធ្វើឡើងនៅក្នុងរឿងក្តី Einsatzgruppen ដែលតុលាការ Nuremberg បានកត់សម្គាល់ថា៖

> តុលាការយោធាអន្តរជាតិដែលដំណើរការអនុលោមតាមធម្មនុញ្ញទីក្រុងឡុងដ៍ បានប្រកាសថា បទប្បញ្ញត្តិនៃធម្មនុញ្ញ បានដាក់កម្រិតឱ្យតុលាការនេះ ពិចារណាតែទៅលើ *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងឡាយណា* ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងពេលប្រព្រឹត្ត ឬដោយជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងឧក្រិដ្ឋកម្មសង្គ្រាមតែប៉ុណ្ណោះ។ នៅក្នុងច្បាប់លេខ ១០ របស់ខ្លួន ក្រុមប្រឹក្សាត្រួតពិនិត្យ បានដកចេញនូវលក្ខខណ្ឌកម្រិតនេះ ដើម្បីអនុញ្ញាតឱ្យ *តុលាការនេះមានយុត្តាធិការជំនុំជម្រះលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងអស់ ដែលត្រូវបានគេយល់ដឹងជាយូរមកហើយទៅតាមគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ*[៤៩]។ (គូសបញ្ជាក់បន្ថែម)

១៧. ជាថ្មីម្តងទៀត នៅពេលលើកឡើងថា ធម្មនុញ្ញនេះ ចែងត្រឹមតែឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមួយចំនួនតែប៉ុណ្ណោះ (ពោលគឺ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តឡើងនៅក្នុងសម័យសង្គ្រាម) តុលាការនេះ ហាក់ដូចជាបានទទួលស្គាល់ថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានអត្ថិភាពឯករាជ្យដាច់ចេញពីធម្មនុញ្ញ Nuremberg ដែលនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងធម្មនុញ្ញនេះ មិនអាចត្រូវបានគេកម្រិតដូចគ្នាឡើយ។ ទោះបីជាយ៉ាងនេះក្តី រឿងក្តីនៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យចំនួន ២ ផ្សេងទៀត ហាក់ដូចជាបានចាត់ទុកលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ថាជាផ្នែកមួយនៃនិយមន័យទូទៅនៃឧក្រិដ្ឋកម្ម

---

[៤៨] រឿងក្តី*Flick និងជនផ្សេងទៀត* ទំព័រ ១២១៣ (សន្និដ្ឋានថា "[យើង] មិនអាចមើលឃើញគោលបំណង ឬ អាណត្តិការងារនៅក្នុងធម្មនុញ្ញនៃតុលាការនេះ ដែលតម្រូវឱ្យតុលាការទទួលយុត្តាធិការលើរឿងក្តីបែបនេះទេ")។

[៤៩] រឿងក្តី *Ohlendorf និងជនផ្សេងទៀត* ទំព័រ ៤៩៩។

ប្រឆាំងនឹងមនុស្សជាតិ ពោលគឺមិនមែនត្រឹមតែជាលក្ខខណ្ឌយុត្តាធិការជាក់លាក់តែប៉ុណ្ណោះនោះទេ។ នៅក្នុងរឿងក្តី *Justice* តុលាការនេះបានលើកឡើងថា៖

> ភស្តុតាងដែលបានពិនិត្យឡើងវិញនៅពេលក្រោយៗមកនេះ បង្ហាញថា អំពើអមនុស្សធម៌មួយចំនួនដូចបានចោទប្រកាន់នៅក្នុងបទចោទទី៣ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានប្រព្រឹត្តឡើងក្នុងពេលធ្វើសង្គ្រាមឈ្លានពាន ឬ ដោយជាប់ពាក់ព័ន្ធនឹងសង្គ្រាមឈ្លានពាន *ហេតុដូច្នេះ វាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ* ទោះបីជាអនុលោមតាមបទប្បញ្ញត្តិនៃធម្មនុញ្ញរបស់ IMT ក៏ដោយ។ ក៏ប៉ុន្តែ គេត្រូវកត់សម្គាល់ថា ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យមានខ្លឹមសារខុសគ្នាពីធម្មនុញ្ញ។ ធម្មនុញ្ញកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថា ជាអំពើអមនុស្សធម៌។ល។ ដែលត្រូវបានប្រព្រឹត្តឡើង "នៅក្នុងពេលប្រព្រឹត្ត ឬដោយជាប់ទាក់ទងនឹងឧក្រិដ្ឋកម្មណាមួយនៅក្រោមយុត្តាធិការរបស់សាលាក្តីនេះ" ខណៈនៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ មិនចែងនូវពាក្យពេចន៍បែបនេះទេ[៥០]។ (គូសបញ្ជាក់បន្ថែម)

១៨. នៅក្នុងរឿងក្តី *Justice* តុលាការនេះហាក់ដូចជាចាត់ទុកលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ថាជាលក្ខណៈពិសេសមួយនៃធម្មនុញ្ញ Nuremberg ហើយទំនងអាចជាធាតុផ្សំសាកលនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផងដែរ។ ទោះបីជាយ៉ាងនេះក្តី ការទទួលស្គាល់របស់តុលាការនេះ លើការដកលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងសង្គ្រាម ចេញពីច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យនោះ បង្ហាញឱ្យឃើញថា តុលាការនេះបានទទួលស្គាល់ថា និយមន័យនៃធម្មនុញ្ញ Nuremberg អំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនមែនជានិយមន័យដែលត្រូវបានគេទទួលស្គាល់ថាមានអត្ថិភាពតែមួយគត់នៅក្នុងពេលនោះឡើយ។

១៩. នៅក្នុងរឿងក្តី *Ministries* តុលាការនេះបានកត់សម្គាល់ថា យុត្តាធិការរបស់ខ្លួនមានលក្ខណៈកម្រិតយោងលើធម្មនុញ្ញ Nuremberg ។ តុលាការលើកឡើងថា អនុលោមតាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ តុលាការមិនអាចធ្វើការបកស្រាយក្នុងលក្ខណៈទូលាយលើយុត្តាធិការរបស់ខ្លួន ដោយបញ្ចូលយុត្តាធិការលើឧក្រិដ្ឋកម្មទាំងឡាយ មិនថាបានប្រព្រឹត្តនៅទីកន្លែងណា

---

[៥០] រឿងក្តី *Alstoetter និងជនផ្សេងទៀត (ការជំនុំជម្រះលើរឿងក្តី Justice)* សាលក្រមចុះថ្ងៃទី ០៣-០៤ ខែ ធ្នូ ឆ្នាំ ១៩៤៧ បោះពុម្ពឡើងវិញនៅក្នុង*ការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា Nuernberg* ក្រោមច្បាប់លេខ ១០ វ៉ុលលីម III ទំព័រ ៩៧៤។

នៅក្នុងពេលណា នោះបានឡើយ[៥១]។ តុលាការនេះបានសម្រេចថា ធម្មនុញ្ញ Nuremberg គឺ ជាការសម្ដែងឥទ្ធិៈលើច្បាប់អន្តរជាតិ ដែលមានអត្ថិភាពនៅក្នុងពេលបង្កើតធម្មនុញ្ញនេះ ចំណែកឯច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ បានពង្រីកហួសហេតុនូវនិយមន័យច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយដាក់បញ្ចូលនូវបទល្មើស ដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិអាល្លឺម៉ង់ ហើយដោយមិនដាក់បញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ។ ហេតុនេះហើយ តុលាការដែលសម្រេចលើរឿងក្ដី *Ministries* បានពិចារណាឃើញថា ខ្លួនមិនមានយុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលពុំមានលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ឡើយ[៥២]។

២០. ហេតុដូច្នេះ រឿងក្ដីនៅក្នុងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ ពុំមានភាពស៊ីសង្វាក់គ្នា លើករណីដែលថាតើលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ គឺជាលក្ខខណ្ឌយុត្តាធិការជាក់លាក់ចំពោះធម្មនុញ្ញ Nuremberg ឬក៏ជាផ្នែកមួយនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងច្បាប់អន្តរជាតិទូទៅ[៥៣]។ យ៉ាងណាក៏ដោយ ចាប់តាំងពីពេលមានឧក្រិដ្ឋកម្មប្រឆាំងនឹង

---

[៥១] *Ernst von Weizsacker និងជនផ្សេងទៀត ការជំនុំជម្រះលើរឿងក្ដី Ministries)* ដីការបស់តុលាការសម្រេចបដិសេធលើបទចោទទី ៤ និងអនុស្សារណៈរបស់តុលាការ ដែលបានភ្ជាប់ជាមួយនឹងដីកាសម្រេចនេះ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៤៨ បោះពុម្ពឡើងវិញនៅក្នុង*ការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាមនៅចំពោះមុខតុលាការយោធា* Nuernberg ក្រោមច្បាប់លេខ ១០ វ៉ុលលឹម XIII ទំព័រ ១១២ ("រឿងក្ដី *Ministries*") ទំព័រ ១១៥-១១៧ (រកឃើញថា បទល្មើសទាំងឡាយដែលបានប្រព្រឹត្តលើជនជាតិអាល្លឺម៉ង់ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងច្បាប់អន្តរជាតិឡើយ ដោយហេតុថា បទល្មើសទាំងនេះមិនបានប្រព្រឹត្តឡើងជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព ឬ ឧក្រិដ្ឋកម្មសង្គ្រាម។

[៥២] រឿងក្ដី*Ministries* ទំព័រ ១១៦ ("សម្រេចថា ឧក្រិដ្ឋកម្មនៅក្នុងនេះ ដែលកំណត់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថាបានប្រព្រឹត្តចំពោះជនជាតិអាល្លឺម៉ង់ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងច្បាប់អន្តរជាតិឡើយ នៅក្នុងពេលប្រព្រឹត្ត។ ពុំមានការអះអាងថា ឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានប្រព្រឹត្តឡើងជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឬ ឧក្រិដ្ឋកម្មសង្គ្រាម ហើយយើងមិនមែនពុំគិតអំពីការដែលថា បទចោទ[ទាំងនេះ] [...] ចោទប្រកាន់លើចុងចោទថាត្រូវទទួលខុសត្រូវលើការប្រព្រឹត្តប្រឆាំងនឹងមនុស្សជាតិចំពោះកម្មវិធីដ៏ទូលំទូលាយនៃភាពសាហាវ និងការធ្វើទុក្ខបុកម្នេញ ដែលពុំដែលបានកត់ត្រាទុកនៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិ")។

[៥៣] *សូមមើលផងដែរ* របាយការណ៍ច្បាប់នៃការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាម គណៈកម្មាការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ វ៉ុលលឹម IX ទំព័រ ៤៥ (ឆ្នាំ ១៩៤៩) និងវ៉ុលលឹម XV ទំព័រ ១៣៦-១៣៧ (ឆ្នាំ ១៩៤៩) (សន្និដ្ឋានថា រឿងក្ដី

មនុស្សជាតិនៅក្នុងនីតិរដ្ឋមាន ការមិនតម្រូវឱ្យមានលក្ខខណ្ឌជម្លោះប្រដាប់អាវុធ បានកើតមានរួចហើយ។ ឯកសារសំអាងផ្លូវច្បាប់ក្រោយៗមកមួយចំនួន បានបកស្រាយលក្ខខណ្ឌទំនាក់ទំនងជាក់លាក់ជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងធម្មនុញ្ញ Nuremberg ថាជាលក្ខខណ្ឌយុត្តាធិការជាក់លាក់នៅក្នុងធម្មនុញ្ញនោះតែប៉ុណ្ណោះ ឬ យ៉ាងហោចណាស់ថា លក្ខខណ្ឌទំនាក់ទំនងចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពុំមានអត្ថិភាពទៀតទេនៅក្នុងករណីណាមួយដែលកើតឡើងមុន និងក្រោយឆ្នាំ ១៩៧៥[៥៤]។

---

*Flick, Justice* និង *Einsatzgruppen* បានទុកបញ្ហាអត្ថិភាពនៃទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ចោលដោយមិនធ្វើការសម្រេចសេចក្តី)។

៥៤ *សូមមើលឧទាហរណ៍* បណ្តឹងសាទុក្ខបន្ទាន់បង្គំរបស់ *Tadić* កថាខណ្ឌ ១៤០ ("ទំនាក់ទនងរវាងក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឬ ឧក្រិដ្ឋកម្មសង្គ្រាម ដែលជាលក្ខខណ្ឌនៅក្នុងធម្មនុញ្ញ Nuremberg មានលក្ខណៈពិសេសចំពោះយុត្តាធិការនៃតុលាការ Nuremberg") គណៈកម្មាការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ *ប្រវត្តិគណៈកម្មាការឧក្រិដ្ឋកម្មសង្គ្រាមនៃអង្គការសហប្រជាជាតិ និងការវិវឌ្ឍនៃច្បាប់សង្គ្រាម* (ឆ្នាំ ១៩៤៨) ទំព័រ ១៩២-១៩៣។ សូមមើល ឯកសារ អ.ស.ប A/CONF. 183/C.1/SR3 ("របាយការណ៍សង្ខេបនៃកិច្ចប្រជុំលើកទី ៣ សន្និសីទអង្គទូតវិសាមញ្ញនៃអង្គការសហប្រជាជាតិស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ" ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨) កថាខណ្ឌ ៨៩ ("ទោះបី ធម្មនុញ្ញតុលាការ Nuremberg និងលក្ខន្តិកៈតុលាការសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានយោងទៅរកជម្លោះប្រដាប់អាវុធ នៅក្នុងរឿងក្តីទាំងពីរ ក៏ដោយលិខិតុបករណ៍ទាំងនេះបានបង្កើតឡើងក្រោយហេតុការណ៍ ហើយពុំបានបង្ហាញថា ទំនាក់ទំនង មានអត្ថិភាពនៅក្នុងច្បាប់អន្តរជាតិ" (យោបល់របស់គណៈប្រតិភូនៃចក្រភពអង់គ្លេស)។ Theodor Meron យោបល់កែសម្រួល *ឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងប្រទេសយូហ្គោស្លាវី និងការវិវឌ្ឍនៃច្បាប់អន្តរជាតិ* ៨៨ AM. J. INT'L L. ៧៨, ៨៥ (ឆ្នាំ ១៩៩៤) ("សាលាក្តី Nuremberg មិនបានពិចារណាលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅមុនសង្គ្រាម ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ [ប៉ុន្តែ] តុលាការនេះអាចទំនងជាមានបទដ្ឋានណែនាំដោយការពិចារណាលើយុត្តាធិការ និងមិនមែនដោយនិយមន័យចង្អៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ")។ Roger S. Clark "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅ Nuremberg" នៅក្នុង*តុលាការ Nuremberg និងច្បាប់អន្តរជាតិ* (Ginsburgs និង Kudriavstev (eds) ឆ្នាំ ១៩៩០) ១៧៧, ១៩៥ ("អ្វីដែល[តុលាការ Nuremberg ចាប់អារម្មណ៍] គឺលើបញ្ហាចោទដោយចង្អៀតលើយុត្តាធិការរបស់ខ្លួន និងបញ្ហាចោទលើអ្វីដែលបានបង្ហាញ ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងបទល្មើសមុនឆ្នាំ ១៩៣៩ និងសង្គ្រាមឈ្លានពាន")។ *សូមមើលផងដែរ Korbely ទល់នឹង* សាលដីកាសេចក្តីសម្រេចលើទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ/២៦ ខែ តុលា ឆ្នាំ ២០១១ /សាធារណៈ

## ៣.២.៣ សេចក្ដីព្រាងក្រមឆ្នាំ ១៩៥៤ របស់គណៈកម្មការនីតិកម្មអន្តរជាតិ

២១. សញ្ញាណដែលថា លក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងធម្មនុញ្ញ Nuremberg គឺជាលក្ខខណ្ឌយុត្តាធិការដាក់លាក់ចំពោះធម្មនុញ្ញនេះ ពោលគឺមិនមែនជាលក្ខខណ្ឌចំបងចំពោះទស្សនទាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះ ក៏មានភាពស៊ីសង្វាក់គ្នាទៅនឹងការងារនៃគណៈកម្មការនីតិកម្មអន្តរជាតិ (“គណៈកម្មការនីតិកម្មអន្តរជាតិ”) ស្ដីពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ។

២២. នៅក្នុងឆ្នាំ ១៩៥០ គណៈកម្មការនីតិកម្មអន្តរជាតិ បានកំណត់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានអនុវត្តនៅក្នុងធម្មនុញ្ញ Nuremberg ដោយបញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ[៥៥]។ ទោះបីជាអាណត្តិការងាររបស់គណៈកម្មការនីតិកម្មអន្តរជាតិកម្រិតត្រឹមតែលើការបង្កើតគោលការណ៍ច្បាប់សម្រាប់អនុវត្តដោយតុលាការ Nuremberg និងមិនមានអំណាចនៅក្នុងការវាយតម្លៃឡើងវិញលើស្ថានភាពនៃច្បាប់ទំនៀមទម្លាប់ក៏ដោយ ក៏អ្នករាយការណ៍ពិសេសនៃគណៈកម្មការនីតិកម្មអន្តរជាតិ បានលើកឡើងនៅក្នុងរបាយការណ៍របស់ខ្លួនដាក់ជូនមហាសន្និបាតនៅក្នុងឆ្នាំ ១៩៥០ ថា “គណៈកម្មការយល់ឃើញថា ឧក្រិដ្ឋកម្ម[ប្រឆាំងនឹងមនុស្សជាតិ] ក៏អាចកើតឡើងនៅមុនពេលសង្គ្រាម ដែលជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពផងដែរ”[៥៦]។

---

អង្គជំនុំជម្រះជាន់ខ្ពស់ (Grand Chamber) នៃតុលាការសិទ្ធិមនុស្សអឺរ៉ុប (លេខ ៩១៧/០២) ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ កថាខណ្ឌ ៨២ ឯកសារ អ.ស.ប A/53/850-S/1999/231 ឧបសម្ព័ន្ធ (“របាយការណ៍ក្រុមអ្នកជំនាញសម្រាប់ប្រទេសកម្ពុជា ដែលបានបង្កើតឡើងយោងតាមសេចក្ដីសម្រេចរបស់មហាសន្និបាតលេខ ៥២/១៣៥” ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧១)។

[៥៥] គោលការណ៍នៃច្បាប់អន្តរជាតិ ដែលទទួលស្គាល់នៅក្នុងធម្មនុញ្ញនៃតុលាការ Nuremberg និងនៅក្នុងសាលក្រមរបស់តុលាការនេះ គោលការណ៍ VI(គ) ដែលបានអនុម័តដោយមហាសន្និបាតនៃ អ.ស.ប ការតម្កល់គោលការណ៍នៃច្បាប់អន្តរជាតិដែលបានទទួលស្គាល់ដោយធម្មនុញ្ញតុលាការ Nurnberg សេចក្ដីសម្រេចរបស់មហាសន្និបាត អ.ស.ប លេខ ៩៣(I) ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៤៦។

[៥៦] “របាយការណ៍របស់គណៈកម្មាការនីតិកម្មអន្តរជាតិនៃមហាសន្និបាត ស្ដីពីការងារក្នុងសម័យប្រជុំលើកទី២” ចុះថ្ងៃទី ០៥ ខែ មិថុនា - ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៥០ (របាយការណ៍ផ្លូវការនៃមហាសន្និបាត សម័យប្រជុំលើកទី៥ ឯកសារបន្ថែមលេខ ១២

00749532



២៣. នៅក្នុងឆ្នាំ ១៩៥៤ គណៈកម្មការនីតិកម្មអន្តរជាតិ បានស្នើសេចក្តីព្រាងក្រមមួយឡើង ដោយបានដាក់បញ្ចូលនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្របទៅតាមរបាយការណ៍របស់អ្នករាយការណ៍ពិសេស ដែលបានដាក់ជូនមហាសន្និបាតនៅក្នុងឆ្នាំ ១៩៥០។ សេចក្តីព្រាងក្រមនេះបានដកចេញលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ[៥៧]។ បើទោះជានិយមន័យនេះមិនត្រូវបានអនុម័តដោយមហាសន្និបាតនៃ អ.ស.ប ក្តី ក៏នេះជាភស្តុតាងអំពីមតិយោបល់ដែលបានពិចារណាយ៉ាងល្អិតល្អន់ពីអ្នកជំនាញច្បាប់ព្រហ្មទណ្ឌអន្តរជាតិមកពីបណ្តាប្រទេសដែលមានការចាប់អារម្មណ៍នៅពេលនោះ។

### ***៣.២.៤ អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨***

២៤. និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងអនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងប្រវត្តិចរចាលើអនុសញ្ញានេះ បង្ហាញឲ្យឃើញទៀតថា លក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ដែលអាចមានអត្ថិភាពក្រោយ Nuremberg ត្រូវបានលុបបំបាត់ចោល។ អនុសញ្ញាឆ្នាំ ១៩៤៨ ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ត្រូវបានអនុម័តដោយសម្លេងឯកច្ឆន្ទដោយមិនបានដាក់បញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ[៥៨]។ នៅក្នុងពេលពិភាក្សាដេញដោលលើសេចក្តីព្រាងអនុសញ្ញានៅក្នុងឆ្នាំ ១៩៤៨ ប្រតិភូប្រទេសក្រិចមួយរូបបានលើកឡើងថា ធម្មនុញ្ញ Nuremberg បានបញ្ចូលឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តឡើងនៅក្នុងពេលសន្តិភាព ហើយឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បង្កើតជាផ្នែកនៃឧក្រិដ្ឋកម្ម

---

បោះពុម្ពផ្សាយឡើងវិញនៅក្នុងសៀវភៅប្រចាំឆ្នាំនៃគណៈកម្មាការនីតិកម្មអន្តរជាតិ៖ ឆ្នាំ ១៩៥០ វ៉ុលលឹម II) ឯកសារ អ.ស.ប លេខ A/1316 កថាខណ្ឌ ១២៣។

[៥៧] "សេចក្តីព្រាងក្រមរបស់គណៈកម្មាការនីតិកម្មអន្តរជាតិស្តីពីបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខមនុស្សជាតិ" ឯកសារ អ.ស.ប លេខ A/2693 (ឆ្នាំ ១៩៥៤)។

[៥៨] *សូមមើល* អនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មាត្រា ១ ("ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនថាបានប្រព្រឹត្តឡើងនៅក្នុងពេលសន្តិភាព ឬ ពេលសង្គ្រាម គឺជាបទល្មើសក្រោមច្បាប់អន្តរជាតិ ដែល [រដ្ឋភាគី] ត្រូវអនុវត្តដើម្បីបង្កា និងដាក់ទណ្ឌកម្ម")។

ប្រឆាំងនឹងមនុស្សជាតិជាក់លាក់មួយ[៥៩]។ លើសពីនេះ សំណើដាក់ជូនក្នុងពេលពិភាក្សាដេញ-ដោលសុំបញ្ចូលឃ្លាដែលសរសេរថា "ទោះបីជាប្រព្រឹត្តក្នុងពេលសន្តិភាព ឬ សង្គ្រាម" ត្រូវបានអនុម័តទទួលយកយ៉ាងឆាប់រហ័ស[៦០]។

២៥. អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថា ការដកយ៉ាងច្បាស់ក្រឡែតនូវលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ចេញពីក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មានភាពស៊ីសង្វាក់គ្នាទៅនឹងវឌ្ឍនភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងអស់។

## ៣.២.៥ អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីអាជ្ញាយុកាល

២៦. ទោះបីជារដ្ឋមួយចំនួនលើកឡើងមតិផ្ទុយពីនេះក៏ដោយ ក៏យើងឃើញមានការគាំទ្រយ៉ាងខ្លាំងក្លាលើការកំណត់និយមន័យយ៉ាងជាក់លាក់ឡើងវិញលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយមិនដាក់បញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងអនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីអាជ្ញា-យុកាល ឡើយ។

២៧. បញ្ហាដែលចោទថាតើអនុសញ្ញានេះគឺជាឱកាសសមស្របនៅក្នុងការកំណត់និយមន័យឡើងវិញលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរឬទេនោះ បង្ហាញនូវភាពចម្រូងចម្រាស់នៅក្នុងអំឡុងពេលចរចា[៦១]។ រដ្ឋខ្លះបានពិចារណាថា ការងារកំណត់និយមន័យលើបទល្មើស គួរទុកឱ្យស្ថាប័នដទៃធ្វើ ខណៈដែលរដ្ឋមួយចំនួនទៀតចាត់ទុកអនុសញ្ញានេះជាឱកាសមួយក្នុងការធ្វើ

---

[៥៩] Schabas ទំព័រ ៨១ ៨៧-៨៨ ("រដ្ឋមួយចំនួនមានការភ័យខ្លាច [ថា ការបញ្ចូលដោយយោងលើសាលក្រម Nuremberg នៅក្នុងបុព្វកថា នៃអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍] នឹងធ្វើឱ្យច្រឡំឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាស្រ័យហេតុនេះ បានកម្រិតទស្សនទាននេះ ពីព្រោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទទួលការបកស្រាយដោយរិតត្បិតនៅតុលាការ Nuremberg ជាពិសេស នៅក្នុងលក្ខខណ្ឌដែលថា ឧក្រិដ្ឋកម្មទាំងនេះបានប្រព្រឹត្តឡើងដោយជាប់ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ")។

[៦០] William A. Schabas *ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងច្បាប់អន្តរជាតិ* (Cambridge 2009 (2nd ed.) ("Schabas") ទំព័រ ៨១។

[៦១] Robert H. Miller *អនុសញ្ញាស្តីពីការមិនអនុវត្តទៅបាននៃអាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ* ៦៥ AM. J. INT'L LAW (ឆ្នាំ ១៩៧១) ("Miller") ៤៧៦,៤៨៥។

00749534



បច្ចុប្បន្នភាពលើនិយមន័យនៃឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៦២]។ នៅទីបំផុត អនុសញ្ញាឆ្នាំ ១៩៦៨ ស្តីពីអាជ្ញាយុកាល បានពង្រីកបញ្ចូលការយោងលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីការប្រកាន់ពូជសាសន៍ និងការជម្លៀសដោយកងកម្លាំងប្រដាប់អាវុធ។ និយមន័យនៅក្នុងអនុសញ្ញា បានដកចេញលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ដោយចែងថា "[គ្មាន]អាជ្ញាយុកាលណាមួយ ត្រូវយកមកអនុវត្តលើបទល្មើសដូចខាងក្រោមនេះ ដោយមិនគិតពីកាលបរិច្ឆេទនៃការប្រព្រឹត្តិឡើយ៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទោះបីប្រព្រឹត្តក្នុងពេលសង្គ្រាមក្តី ឬ ក្នុងពេលសន្តិភាពក្តី ដូចមានចែងនៅក្នុងធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិនៅ Nürnberg នាថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៤៥"[៦៣]។

២៨. យោងតាមចំណុចនេះ អនុសញ្ញានេះ ក៏បញ្ជាក់បំភ្លឺផងដែរថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក៏អាចត្រូវបានប្រព្រឹត្តក្នុងពេលសន្តិភាព។ ម៉្យាងវិញទៀត និយមន័យនីមួយៗនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានពិចារណាដោយក្រុមការងារលើលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ក៏បានបង្ហាញនូវការឯកភាពជាឯកច្ឆន្ទក្នុងចំណោមសមាជិកក្រុមការងារផងដែរថា លក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ពុំមែនជាផ្នែកមួយនៃច្បាប់អន្តរជាតិ ដូចកាលពីមុនទៀតឡើយ[៦៤]។

២៩. ទោះបីជាអនុសញ្ញាស្តីពីអាជ្ញាយុកាល ពុំទទួលបានការគាំទ្រខ្លាំងក្លាក្តី ការជំទាស់ទៅនឹងអនុសញ្ញានេះ ភាគច្រើនផ្អែកលើមូលដ្ឋាននៃការដាក់បញ្ចូលឧក្រិដ្ឋកម្មនៃការប្រកាន់ពូជសាសន៍ និងការជម្លៀសដោយការវាយប្រហារដោយអាវុធ ឬ ការកាន់កាប់នៅក្នុងអនុសញ្ញានេះ[៦៥]។ អង្គជំនុំជម្រះ

---

[៦២] Miller ទំព័រ ៤៨៥។

[៦៣] អនុសញ្ញាស្តីពីអាជ្ញាយុកាល មាត្រា ១(ខ)។

[៦៤] គណៈកម្មការសិទ្ធិមនុស្ស របាយការណ៍ក្នុងសម័យប្រជុំលើកទី២៣ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៦៧-ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៦៧ ទំព័រ ៤៥-៤៦។

[៦៥] Miller ទំព័រ ៤៩០-៤៩១។ *សូមមើលផងដែរ* គណៈកម្មការសិទ្ធិមនុស្ស របាយការណ៍ក្នុងសម័យប្រជុំលើកទី២៣ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៦៧-ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៦៧ ទំព័រ ១៤៤-១៤៥ (ការពិភាក្សាដេញដោលរបស់គណៈកម្មការសិទ្ធិមនុស្សលើសេចក្តីព្រាងអនុសញ្ញាស្តីពីអាជ្ញាយុកាល ដែលក្នុងពេលនោះ តំណាងខ្លះយល់ឃើញថា សេចក្តីព្រាងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានវិសាលភាពលក្ខណៈចង្អៀត នៅពេលយោងទៅរកធម្មនុញ្ញ Nuremberg។ តំណាងផ្សេង

សាលាដំបូង ចាត់ទុកមតិយោបល់នានារបស់រដ្ឋទាំងឡាយអំពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ថាជាមតិយោបល់សំខាន់នៅក្នុងការបង្កើតបានជា *សច្ចធារណ៍ធម្មានុរូប* លើលក្ខខណ្ឌស្តីពីទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ចាប់ពីឆ្នាំ១៩៦៨ រហូតមក។

## ***៣.២.៦ អនុសញ្ញាឆ្នាំ ១៩៧៣ ស្តីពីការប្រកាន់ពូជសាសន៍***

៣០. អនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍ ក៏បានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្តីពីការប្រកាន់ពូជសាសន៍ផងដែរ ក៏ប៉ុន្តែ ដោយពុំមានការយោងណាមួយទៅរកជម្លោះប្រដាប់អាវុធឡើយ[៦៦]។ នៅក្នុងពេលពិភាក្សាដេញដោល ឈានទៅរកការអនុម័តអនុសញ្ញានេះ ប្រតិភូមកពីចក្រភពអង់គ្លេសមួយរូប បានលើកឡើងថា ធម្មនុញ្ញ Nuremberg និងគោលការណ៍ Nuremberg បានចែងអំពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយពុំមានការពង្រីកអត្ថន័យបន្ថែមនាពេលក្រោយៗមកទៀតនោះទេ។ ហេតុដូច្នេះ ប្រតិភូរូបនេះបានស្នើឡើងថា ការប្រកាន់ពូជសាសន៍ពុំបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ យោងតាមន័យចង្អៀតរបស់ច្បាប់ ហើយវាជាកំហុសមួយ ក្នុងការកែប្រែនិយមន័យជាធរមាននេះ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់លាក់ណាមួយនោះ[៦៧]។ មតិយោបល់នេះត្រូវបានច្រានចោល ហើយអនុសញ្ញានេះត្រូវបានអនុម័តនៅថ្ងៃ

---

ទៀតបានលើកឡើងថា ទស្សនទាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានបង្កើតឡើងនៅតុលាការ Nuremberg ហើយបទល្មើសមួយចំនួន ដែលទទួលទោស ដោយមិនគិតថាមានការជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឬ ឧក្រិដ្ឋកម្មសង្គ្រាម ត្រូវបានកំណត់នៅក្នុងអនុសញ្ញាស្តីពីប្រល័យពូជសាសន៍ និងផ្នែកខ្លះនៃអនុសញ្ញាទីក្រុងហ្សឺណែវ។ ទោះបីជាយ៉ាងនេះក្តី តំណាងទាំងនេះយល់ឃើញថា រដ្ឋនីមួយៗអាចអនុវត្តច្បាប់អន្តរជាតិជាធរមាន ក្នុងការដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលពុំជាប់ពាក់ព័ន្ធនឹងស្ថានភាពសង្គ្រាម។ ការបោះឆ្នោតពុំបានធ្វើឡើងលើបញ្ហានេះឡើយ)។

[៦៦] មាត្រា I និង II អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍ សេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប លេខ ៣០៦៨ (XXVIII) ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៣ (បានអនុម័តនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៣)។ របបកម្ពុជាប្រជាធិបតេយ្យបានចូលជាភាគីនៃអនុសញ្ញានេះនៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៨១ (*សូមមើល* កម្រងសន្ធិសញ្ញាអង្គការសហប្រជាជាតិ ជំពូក IV(៧) អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍ ឋានៈនៃសន្ធិសញ្ញា)។

[៦៧] ឯកសារ អ.ស.ប A/C.3/SR.1863 គណៈកម្មាធិការទី៣ សម័យប្រជុំលើកទី១៨៥៩ ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៧១ ទំព័រ ២៤៩។

ទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៣[៦៨]។ ក្រោយមក កម្ពុជាប្រជាធិបតេយ្យ បានចូលជាភាគីនៃអនុសញ្ញាស្តីពីការប្រកាន់ពូជសាសន៍នេះ ដោយ អៀង សារី បានចុះហត្ថលេខានៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៨១[៦៩]។

## ***៣.២.៧ វិវឌ្ឍន៍ក្រោយឆ្នាំ ១៩៧៩***

៣១. វិវឌ្ឍន៍ក្រោយៗមកទៀតនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ មានលក្ខណៈស្របនឹងការសន្និដ្ឋានថា ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ លែងជាផ្នែកមួយនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៀតហើយ គិតត្រឹមពេលបង្កើតតុលាការ *មិនអចិន្ត្រៃយ៍* នានា។ ឧទាហរណ៍ ទោះជាលក្ខន្តិកៈរបស់តុលាការ ICTY ឆ្នាំ ១៩៩៣ ពិតជាបានបញ្ចូលលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនៅក្នុងលក្ខខណ្ឌទូទៅនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY បានបញ្ជាក់ថា ការបញ្ចូលលក្ខខណ្ឌនេះគឺជាលក្ខណៈពិសេសមួយនៃលក្ខន្តិកៈរបស់តុលាការ ICTY ដែលពុំមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ[៧០]។ ម្យ៉ាងវិញទៀត លក្ខន្តិកៈរបស់តុលាការ ICTR ឆ្នាំ ១៩៩៤ និងលក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ឆ្នាំ ២០០០ ពុំបានដាក់បញ្ចូលចំណងទាក់ទងណាមួយជាមួយនឹងជម្លោះប្រដាប់អាវុធ នៅក្នុងនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែល

---

[៦៨] សេចក្តីសម្រេចរបស់មហាសន្និបាត អ.ស.ប លេខ ៣០៦៨ (XXVIII) ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៣ (អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍)។

[៦៩] កម្រងសន្ធិសញ្ញាអង្គការសហប្រជាជាតិ ជំពូក IV(៧) អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មប្រកាន់ពូជសាសន៍។ របបកម្ពុជាប្រជាធិបតេយ្យបានចូលជាភាគីនៃអនុសញ្ញានេះនៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៨១ (ឯកសារដាក់នៅអង្គជំនុំជម្រះសាលាដំបូង)។

[៧០] លក្ខន្តិកៈតុលាការ ICTY មាត្រា ៥។ *រដ្ឋអាជ្ញា ទល់នឹង Tadić* សេចក្តីសម្រេចលើសំណើបន្ទាន់បង្ខំរបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងបញ្ហាយុត្តាធិការ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY (សំណុំរឿងលេខ IT-94-1-A) កថាខណ្ឌ ១៤០។ *សូមមើលផងដែរ រដ្ឋអាជ្ញា ទល់នឹង Tadic* សាលដីកា អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តី ICTY (រឿងក្តីលេខ IT-94-1-A) ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ កថាខណ្ឌ ២៥១ ("លក្ខខណ្ឌជម្លោះប្រដាប់អាវុធ បានបំពេញតាមភស្តុតាងបង្ហាញថាមានជម្លោះប្រដាប់អាវុធ កើតឡើង។ នេះជាអ្វីដែលលក្ខន្តិកៈនេះតម្រូវ ហើយនៅពេលតម្រូវដូច្នេះ វាទាមទារច្រើនជាងលក្ខខណ្ឌនៃច្បាប់ទំនៀមទម្លាប់ អន្តរជាតិ")។

អនុវត្តជាធរមាននៅចំពោះមុខតុលាការទាំងនេះឡើយ[៧១]។

៣២. នៅក្នុងសម័យប្រជុំលើកទីមួយរបស់គណៈកម្មាធិការរៀបចំបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ មានការឯកភាពជាឯកច្ឆន្ទថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពុំចាំបាច់កម្រិតត្រឹមតែអំពើនៅក្នុងពេលសង្គ្រាមឡើយ[៧២]។ ទោះបីជាយ៉ាងនេះក្តី ប្រតិភូមកពីប្រទេសចិន និងសហព័ន្ធរុស្ស៊ី បានបង្ហាញទស្សនៈថា ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ មានសារៈសំខាន់ជាចាំបាច់[៧៣]។ សេចក្តីសង្ខេបនៅក្នុងសម័យប្រជុំលើកទីមួយរបស់គណៈកម្មាធិការរៀបចំ បានរាយការណ៍ថា ប្រតិភូមួយចំនួនបានបង្ហាញទស្សនៈថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពុំចាំបាច់ជាប់ទាក់ទងនឹងជម្លោះយោធាឡើយ ខណៈប្រតិភូឯទៀត អំពាវនាវឱ្យភ្ជាប់ទំនាក់ទំនងនេះ[៧៤]។ ទោះបីជានៅក្នុងពេលសន្និសីទនាទីក្រុងរ៉ូមនាថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៨ ប្រតិភូមួយចំនួន បានបង្ហាញទស្សនៈថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាមទារឱ្យមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធក៏ដោយ ក៏លក្ខន្តិកៈទីក្រុងរ៉ូម នៅពេលចុងក្រោយ ត្រូវបានអនុម័តដោយពុំបានយោងទៅលក្ខខណ្ឌទំនាក់ទំនងនេះឡើយ[៧៥]។ ហេតុដូច្នេះ នៅត្រឹមឆ្នាំ ១៩៩៨ វាមិនមានការសង្ស័យទេថា

---

[៧១] លក្ខន្តិកៈតុលាការ ICTR មាត្រា ៣។ លក្ខន្តិកៈរបស់តុលាការ SCSL មាត្រា ២។

[៧២] របាយការណ៍គណៈកម្មាធិការ *មិនអចិន្ត្រៃយ៍*ស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិពិភាក្សា អំពីនិយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (សេចក្តីប្រកាសព័ត៌មានរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៦ ឯកសារ UN Doc. L/2762។

[៧៣] "វាគ្មិននៅក្នុងគណៈកម្មាធិការរៀបចំសម្រាប់តុលាការអន្តរជាតិបាននិយាយថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវតែកំណត់ឱ្យបានច្បាស់លាស់" (សេចក្តីប្រកាសព័ត៌មាន អ.ស.ប ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៦) ឯកសារ អ.ស.ប L/276/វិ. លើកទី១។

[៧៤] "គណៈកម្មាធិការរៀបចំស្តីពីតុលាការព្រហ្មទណ្ឌពិសេសបានបញ្ចប់សម័យប្រជុំលើកទី១" (សេចក្តីប្រកាសព័ត៌មាន អ.ស.ប ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៩៦) ឯកសារ អ.ស.ប L/2787 ទំព័រ៤។

[៧៥] "សន្និសីទអគ្គទូតវិសាមញ្ញនៃអង្គការសហប្រជាជាតិស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ របាយការណ៍សង្ខេបនៃកិច្ចប្រជុំលើកទី៣" ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ឯកសារ អ.ស.ប A/CONF.183/C.1/SR.3 (ការយល់ឃើញបានលើកឡើងខុសៗគ្នាថាតើគួរតែមានទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធដែរឬទេ។ គណៈប្រតិភូខ្លះ ក៏មានបំណងចង់កម្រិត "ជម្លោះប្រដាប់អាវុធ" ត្រឹមតែជម្លោះប្រដាប់អាវុធអន្តរជាតិតែប៉ុណ្ណោះ" (សេចក្តីថ្លែងការណ៍បញ្ចប់របស់ប្រធាន))។ *សូមមើលផងដែរ* W.Schabas *តុលាការព្រហ្មទណ្ឌអន្តរជាតិ៖ សេចក្តីអត្ថាធិប្បាយស្តីពីលក្ខន្តិកៈទីក្រុងរ៉ូម* (Oxford

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពុំមានភ្ជាប់លក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះ ប្រដាប់អាវុធ ឡើយ។

### ៣.២.៨ សេចក្តីសន្និដ្ឋាន

៣៣. ក្រោយពីបានពិនិត្យមើលឡើងវិញលើការអនុវត្តរបស់រដ្ឋ និង*សច្ចធារណ៍ធម្មានុរូប* ដែលមានការពាក់ព័ន្ធនៅចន្លោះឆ្នាំ ១៩៤៥ និងឆ្នាំ ១៩៧៥ មក អង្គជំនុំជម្រះសាលាដំបូងសន្និដ្ឋានថា ចាប់តាំងពីការកកើតឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងធម្មនុញ្ញ Nuremberg និងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ យើងឃើញមាននិន្នាការសំខាន់មួយរួចហើយនៃការមិនដាក់លក្ខខណ្ឌទំនាក់ទំនងឧក្រិដ្ឋកម្មទាំងនេះជាមួយនឹងជម្លោះប្រដាប់អាវុធ។ និន្នាការនេះ គឺថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ដោយមិនជាប់ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ បានចាប់ផ្តើមវិវឌ្ឍន៍ខ្លាំងនៅក្រោយសម័យ Nuremberg ហើយរហូតបានបង្កើតជាច្បាប់ដោយមានការឯកភាពមួយនៅត្រឹមឆ្នាំ ១៩៧៥។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងតម្កល់ការយល់ឃើញរបស់ខ្លួននៅក្នុងសំណុំរឿង ០០១ ដែលថា ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ពុំមែនជាផ្នែកមួយនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ឡើយ។

**យោងលើសំអាងហេតុដូចបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង ÷**

**ប្រកាសថា** សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអាចទទួលយកបានតាមទម្រង់។

---

2010) ទំព័រ ១៤៦-១៤៧ (កត់សម្គាល់ថា ក្នុងពេលសន្និសីទនៅទីក្រុងរ៉ូម ប្រតិភូមួយចំនួនយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនអាចប្រព្រឹត្តនៅក្នុងពេលសន្តិភាពបានឡើយ)។ ធាតុផ្សំទូទៅនៃមាត្រា ៧ នៃលក្ខន្តិកៈរបស់តុលាការ ICC ដែលបានអនុម័តនាពេលចុងក្រោយ បានចែងថា៖ “សម្រាប់គោលបំណងនៃលក្ខន្តិកៈនេះ “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” មានន័យថា អំពើដូចខាងក្រោយ ដែលបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារជាលក្ខណៈទូទៅ ឬ ជាលក្ខណៈប្រព័ន្ធ លើប្រជាជនស៊ីវិល ដោយបានដឹងអំពីការវាយប្រហារនោះ...”។

**រកឃើញ និងប្រកាសថា** និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នាចន្លោះឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៩ ពុំតម្រូវឱ្យបង្ហាញពីលក្ខខណ្ឌទំនាក់ទំនងរវាងអំពើល្មើសជាក់លាក់ ជាមួយនឹងជម្លោះប្រដាប់អាវុធឡើយ។

**ឯកភាពតាម** សំណើសុំរបស់សហព្រះរាជអាជ្ញា និងដកលក្ខខណ្ឌទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធចេញពីក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលនឹងត្រូវអនុវត្តនៅក្នុងសំណុំរឿង ០០២។

**បដិសេធ** សំណើរបស់ អៀង សារី ស្នើសុំឱ្យបើកសវនាការដេញដោលលើបញ្ហានេះ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១១

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C.

**និល ណុន**